Intersections of Our Lives

# បញ្ហាយុត្តិធម៌នៃសុខភាពបន្តពូជគឺជាអាទិភាពកំពូលសម្រាប់អ្នកបោះឆ្នោតស្ត្រី AAPI

ក្រុមមួយដែលមានឈ្មោះថា *Intersections of Our Lives* ដែលបានចាប់ដៃគូរជាមួយ អង្គការដែលតស៊ូដើម្បីសិទ្ធបន្តពូជរបស់ស្ត្រី និងតំណាងឲ្យស្ត្រីដែលមានពណ៌សម្បុរ បានរៀបចំការស្ទង់មតិដ៏ធំមួយ។ ពួកគេបានសួរទៅកាន់ស្ត្រីជនជាតិអាស៊ី-អាមេរិកដែលរស់នៅកោះប៉ាស៊ីហ្វិក *Asian American Pacific Islander (AAPI)* ចំនួន ៨៥០នាំ ដែលបានចុះឈ្មោះបោះឆ្នោត, ស្ត្រីជនជាតិស្បែកខ្មៅចំនួន ៨៥០នាក់ដែលបានចុះឈ្មោះបោះឆ្នោត និងស្ត្រីជនជាតិឡាទីន ៨៥០នាក់ដែលបានចុះឈ្មោះបោះឆ្នោត អំពីបទពិសោធន៍របស់ពួកគេ និងអ្វីដែលសំខាន់បំផុតក្នុងជីវិតរបស់ពួកគេ។ ពួកគេបានរកឃើញថា ខណៈពេលដែលក្រុមទាំងបី យកចិត្តទុកដាក់ទៅលើរឿងដែលស្រដៀងគ្នា, បញ្ហាមួយចំនួនមានសារៈសំខាន់ ជាពិសេសចំពោះអ្នកបោះឆ្នោតស្ត្រី *AAPI*។

## ទិដ្ឋភាពទូទៅ

ការស្ទង់មតិរបស់យើងទៅលើស្ត្រីដែលមានពណ៌សម្បុរដែលបោះឆ្នោតទូទាំងប្រទេសបានបង្ហាញថា ស្ត្រីជនជាតិអាស៊ីអាមេរិក ដែលរស់នៅលើកោះប៉ាស៊ីហ្វិក (AAPI) ជនជាតិស្បែកខ្មៅ និងជនជាតិឡាទីន មានកង្វល់ទូទៅជាច្រើន។ ជាពិសេសទាក់ទងនឹងបញ្ហាយុត្តិធម៌នៃសិទ្ធបន្តពូជ ដូចជាសន្តិសុខសេដ្ឋកិច្ច/ឱកាស និងសិទ្ធិរំលូតកូន ស្ត្រីមានពណ៌សម្បុរយល់ស្របៈ អ្នកនយោបាយរបស់យើងត្រូវតែកែលម្អ។ វាមានសារៈសំខាន់ក្នុងការគូសបញ្ជាក់ពីអាទិភាពទូទៅទាំងនេះ ប៉ុន្តែវាក៏សំខាន់ផងដែរក្នុងការទទួលស្គាល់តម្រូវការជាក់លាក់របស់សហគមន៍នីមួយៗ។ ខាងក្រោមនេះនេះគឺជាការរកឃើញសំខាន់ៗមួយចំនួនទាក់ទងនឹងបទពិសោធន៍ និងទស្សនៈរបស់ស្ត្រី AAPI ។

## ការយល់ដឹង

ស្ត្រី AAPI គឺជាប្លុកបោះឆ្នោតដ៏សំខាន់មួយនៅក្នុងការបោះឆ្នោតឆ្នាំ ២០២៤ ហើយ ៩០% មានការពេញចិត្តយ៉ាងខ្លាំង ក្នុងការបោះឆ្នោត។ ៦២% នៃស្ត្រី AAPI មើលឃើញថាការបោះឆ្នោតមានសារៈសំខាន់ខ្លាំងណាស់។ ទោះជាយ៉ាងណាក៏ដោយមានតែ ៥២% ប៉ុណ្ណោះដែលមើលឃើញថាការបោះឆ្នោតមានប្រសិទ្ធភាពខ្លាំងក្នុងការបង្កើតការផ្លាស់ប្តូរដែលពួកគេចង់បាន។ ការរកឃើញនេះបានបង្ហាញឲ្យយើងឃើញអំពីការខកចិត្តដែលស្ត្រី AAPI មានអារម្មណ៍ថាមិនបានឃើញ ការព្រួយបារម្ភណ៍ និងអាទិភាពរបស់ពួកគេ ត្រូវបានដោះស្រាយនៅក្នុងនយោបាយ ឬគោលនយោបាយផ្សេងៗ។

សម្រាប់ស្ត្រី AAPI ការបោះឆ្នោតរបស់ពួកគេតំណាងឱ្យតម្លៃរបស់ពួកគេ។ ពួកគេត្រូវបានជំរុញជាចម្បងដោយការព្រួយបារម្ភរបស់ពួកគេ អំពីបញ្ហាជាតិ និងសង្គម។ ភាគច្រើន (៥៥%) នៃស្ត្រី AAPI មានអារម្មណ៍ថាអ្វីៗកាន់តែអាក្រក់ទៅៗនៅក្នុងប្រទេស។

ស្នូលនៃយុត្តិធម៌សិទ្ធបន្តពូជ គឺជាជំនឿដែលស្ត្រីគ្រប់រូបមានសិទ្ធិមានកូន សិទ្ធិមិនចង់មានកូន និងសិទ្ធិចិញ្ចឹមកូនដែលយើងមានក្នុងបរិយាកាសដែលមានសុវត្ថិភាព និងមានសុខភាពល្អ។

សហគមន៍ AAPI មានភាពចម្រុះជាតិសាសន៍មិនមែនដូចគ្នាទាំងអស់នោះទេ។ វារួមបញ្ចូលមនុស្សដែលមកពីសាវតាជនជាតិផ្សេងៗគ្នា និងមានបទពិសោធន៍ជីវិតផ្សេងៗគ្នា។ ការស្ទង់មតិនេះបានធ្វើឡើង ដោយប្រាកដថានឹងរួមបញ្ចូលមនុស្សកាន់តែច្រើនពីក្រុមជនជាតិជាក់លាក់ដូចជាជនជាតិ ចិន ហ្វីលីពីន ឥណ្ឌា កូរ៉េ និងវៀតណាមជាដើម។

កង្វល់ដ៏ធំបំផុតដែលប៉ះពាល់ដល់របៀបដែលស្ត្រី AAPI នឹងបោះឆ្នោតនៅឆ្នាំនេះគឺការកើនឡើងនៃការចំណាយ។ នេះជាការពិតសម្រាប់ក្រុមជនជាតិភាគតិចទាំងអស់ដែលបានធ្វើការស្ទង់មតិ លើកលែងតែស្ត្រីជនជាតិកូរ៉េ ដែលកង្វល់ចម្បងរបស់ពួកគេគឺសិទ្ធិស្ត្រី។ សរុបមក សិទ្ធិស្ត្រីជាប់ចំណាត់ថ្នាក់ទី ២ ក្នុងសារៈសំខាន់សម្រាប់ស្ត្រី AAPI ប៉ុន្តែក្លាយជាអាទិភាពកំពូលនៅពេលរួមបញ្ចូលជាមួយសិទ្ធិរំលូតកូន។

ក្នុងចំណោមបញ្ហាអាទិភាពផ្នែកសេដ្ឋកិច្ច ការងារដែលមានប្រាក់ខែល្អ លទ្ធភាពនៃការទទួលបានការថែទាំសុខភាព និងលំនៅឋានដែលមានតម្លៃសមរម្យ។ ការធានាសម្រាប់គ្រួសារ ថាអាចមានប្រាក់ខែ នៅពេលឈប់សម្រាកព្យាបាលគឺមានសារៈសំខាន់បំផុតសម្រាប់សភាក្នុងការដោះស្រាយ។ អត្រាមរណៈមាតាពេលសំរាលកូនក្នុងចំណោមស្ត្រីដែលមានពណ៌សម្បុរ ការទទួលបានថ្នាំរំលូតកូន និងការទទួលបានសិទ្ធិពន្យារកំណើត គឺជាអាទិភាពខ្ពស់បំផុតនៅពេលនិយាយអំពីសុខភាពបន្តពូជ ដោយ ៧៩%, ៧៨%, និង ៧៧% នៃស្ត្រី AAPI និយាយថាវាមានសារៈសំខាន់ខ្លាំងណាស់ ឬសំខាន់រៀងៗខ្លួន។ ៧៥% ចាត់ទុកលទ្ធភាពនៃការរំលូតកូនថាជារឿងសំខាន់ ឬសំខាន់ខ្លាំងណាស់។

សរុបមក ៧២% នៃស្ត្រី AAPI គាំទ្រសិទ្ធិរំលូតកូន។ ទោះបីជាមានមតិខុសគ្នាខ្លះអំពីការរំលូតកូនក្នុងចំណោមជនជាតិផ្សេងៗគ្នាក៏ដោយ ភាគច្រើនជឿថាការរំលូតកូនគួរតែស្របច្បាប់ក្នុងស្ថានភាពជាច្រើន ឬគ្រប់កាលៈទេសៈ។

នៅពេលពិភាក្សាអំពីទស្សនៈរបស់ពួកគេលើការរំលូតកូន,ស្ត្រី AAPI សង្កត់ធ្ងន់លើសារៈសំខាន់នៃការសម្រេចចិត្តជាបុគ្គល ការទទួលបានសិទ្ធិរំលូតកូនដែលប្រកបដោយសុវត្ថិភាព និងតម្លៃសមរម្យដោយគ្មានការវិនិច្ឆ័យ ឬការដាក់ទណ្ឌកម្ម និងសមត្ថភាពក្នុងការគ្រប់គ្រងរាងកាយ និងជីវិតរបស់ពួកគេផ្ទាល់។

៨៤% នៃស្ត្រី AAPI ជឿថាការរើសអើងជាតិសាសន៍បានអូសបន្លាយយូរពេកនៅក្នុងសហរដ្ឋអាមេរិក ហើយកំពុងស្វែងរកអ្នកដឹកនាំដែលនឹងបង្កើតប្រព័ន្ធយុត្តិធម៌ពូជសាសន៍ដែចាស់បូរាណនេះ។ លើសពីនេះទៀត ៨៣% មានអារម្មណ៍ថាវាមានសារៈសំខាន់សម្រាប់សភាក្នុងការដោះស្រាយបញ្ហារនៃការរើសអើងជាតិសាសន៍/ជនជាតិភាគតិច និងការប្រឆាំងនឹងអំពើហឹង្សាដែលទាក់ទងនឹង AAPI ។ ទោះជាយ៉ាងណាក៏ដោយ ៥៤% មានអារម្មណ៍ថាពួកគេមិនបានឃើញបុគ្គលដូចជាខ្លួនឯងបានតស៊ូមតិចំពោះបញ្ហាដែលពួកគេយកចិត្តទុកដាក់នោះទេ។

អាទិភាពគោលនយោបាយចម្បងសម្រាប់ស្ត្រី AAPI រួមមាន៖ការព្រួយបារម្ភអំពីសុវត្ថិភាពដូចជាកំណែទម្រង់យុត្តិធម៌ព្រហ្មទណ្ឌ ការការពារអំពើហិង្សាដោយកាំភ្លើង និងការកាត់បន្ថយឧក្រិដ្ឋកម្ម ក៏ដូចជាកង្វល់ផ្នែកសេដ្ឋកិច្ចដូចជាការបង្កើតការងារដែលមានប្រាក់ខែល្អ និងការទទួលបានការថែទាំសុខភាព និងលំនៅដ្ឋានដែលមានតម្លៃសមរម្យ។




Intersections of Our Lives

napawf
NATIONAL ASIAN PACIFIC AMERICAN WOMEN'S FORUM

National Latina Institute for Reproductive Justice

voice
National Black Women's Reproductive Justice Agenda

## ចំណុចសំខាន់ដែលត្រូវចងចាំ

- ស្ត្រី AAPI បានរកឃើញរាល់បញ្ហាដែលត្រូវបានធ្វើតេស្ត – ចាប់ពីបញ្ហាសន្តិសុខសេដ្ឋកិច្ច រហូតដល់បញ្ហាសុវត្ថិភាព និងបញ្ហានៃការរើសអើង រហូតដល់បញ្ហាថែទាំសុខភាពបន្តពូជ – មានសារៈសំខាន់សម្រាប់អ្នកនយោបាយក្នុងការដោះស្រាយ និងឈានទៅមុខក្នុងរយៈពេលពីរឆ្នាំខាងមុខ។ ស្ត្រី AAPI ត្រូវការផែនការដ៏ទូលំទូលាយមួយដែលទទួលស្គាល់ និងគោរពបទពិសោធន៍ ជីវិត និងអាទិភាព របស់ពួកគេ។
- ស្រដៀងគ្នាទៅនឹងស្ត្រីដែលមានពណ៌សម្បុរផ្សេងទៀត ស្ត្រី AAPI ចាត់ទុកថាការបោះឆ្នោតមានសារៈសំខាន់ ហើយនឹងត្រូវជះឥទ្ធិពលយ៉ាងខ្លាំងដោយបញ្ហាសេដ្ឋកិច្ច និងការបន្តពូជនៅពេលធ្វើការសម្រេចចិត្តបោះឆ្នោតរបស់ពួកគេ។
- ច្រើនជាងក្រុមដ៏ទៃទៀត ស្ត្រី AAPI ត្រូវបានជំរុញដោយតម្លៃផ្ទាល់ខ្លួនរបស់ពួកគេនៅពេលនិយាយអំពីការបោះឆ្នោត។
- ការកើនឡើងថ្លៃរស់នៅ និងតម្លៃទំនិញ (៣៣%) គឺជាបញ្ហាដ៏សំខាន់បំផុតក្នុងការបោះឆ្នោតសម្រាប់ស្ត្រី AAPI ជារួម និងសម្រាប់ក្រុមជនជាតិដ៏ទៃទៀត បន្ទាប់មកដោយសិទ្ធិស្ត្រី (២៣%) ។ បន្ទាប់មកទៀតគឺការគំរាមកំហែងដល់លទ្ធិប្រជាធិបតេយ្យ (១៦%) ការរំលូតកូន (១៥%) លំនៅដ្ឋានតម្លៃសមរម្យ (១៤%) និងអន្តោប្រវេសន៍ (១៤%) ។
- សម្រាប់បញ្ហាសេដ្ឋកិច្ច ស្ត្រី AAPI បានរកឃើញថាវាមានសារៈសំខាន់បំផុតសម្រាប់សភាក្នុងការបង្កើតការងារដែលមានប្រាក់ខែល្អ (៨៩%) ធានាថាគ្រប់គ្នាមានលទ្ធភាពទទួលបានការថែទាំសុខភាពដែលមានតម្លៃសមរម្យ (៨៥%) សំរេចឲ្យមាន កម្មវិធីដែលធានាដល់គ្រួសារ ថានឹងមានប្រាក់ឈ្នួល នៅពេលឈប់សម្រាកព្យាបាល (៨៥%) និងបង្កើតជម្រើសលំនៅដ្ឋានដែលមានតម្លៃសមរម្យជាងមុន (៨២%)។
- សម្រាប់បញ្ហាសុខភាពបន្តពូជ និងការរំលូតកូន ស្ត្រី AAPI បានរកឃើញថាវាមានសារៈសំខាន់បំផុតសម្រាប់សភាក្នុងការដោះស្រាយអត្រាខ្ពស់នៃការស្លាប់របស់មាតាក្នុងចំណោមស្ត្រីដែលមានពណ៌សម្បុរ (៧៩%) ធានាថាការរំលូតកូនដោយថ្នាំមានសម្រាប់ស្ត្រីគ្រប់រូបមិនថាពួកគេរស់នៅទីណាទេ (៧៨% ) និងធានាបាននូវសិទ្ធិទទួលបានការពន្យារកំណើត (៧៧%)។
- សម្រាប់បញ្ហាសុវត្ថិភាព, ស្ត្រី AAPI បានរកឃើញថាវាមានសារៈសំខាន់បំផុតសម្រាប់សភាដើម្បីធ្វើកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឲ្យវាដំណើរការដោយយុត្តិធម៌ និងសមធម៌ (៩០%) ការពារសហរដ្ឋអាមេរិកពីភេរវករ (៨៤%) និងបង្ក្រាបឧក្រិដ្ឋកម្ម (៨២%)។
- សម្រាប់បញ្ហាយុត្តិធម៌ជាតិសាសន៍, ស្ត្រី AAPI បានរកឃើញថាវាមានសារៈសំខាន់បំផុតសម្រាប់សភាក្នុងការបញ្ចប់ការរើសអើងប្រឆាំងនឹងមនុស្សដោយសារតែជាតិសាសន៍ ជនជាតិ ឬវប្បធម៌របស់ពួកគេ (៨៣%), ដោះស្រាយការរើសអើងជាតិសាសន៍/ជនជាតិ និងការប្រឆាំងនឹង AAPI, អំពើហិង្សាដែលទាក់ទងនឹងការស្អប់ (៨៣% ) ហើយឈប់ធ្វើឱ្យក្រុមមួយចំនួនមានការពិបាកក្នុងការបោះឆ្នោត (៧៩%)។
- ស្ត្រី AAPI បានសង្កត់ធ្ងន់លើសារៈសំខាន់នៃសភាដែលធានានូវលទ្ធភាពទទួលបានការថែទាំសុខភាពសម្រាប់មនុស្សគ្រប់រូបដោយមិនគិតពីស្ថានភាពអន្តោប្រវេសន៍របស់ពួកគេនៅ ៧៤%,នេះបញ្ជាក់ពីចំណុចប្រសព្វនៃការថែទាំសុខភាព និងបញ្ហាអន្តោប្រវេសន៍។
- ស្ត្រី AAPI មានគម្រោងទៅបោះឆ្នោតដោយផ្ទាល់ នៅថ្ងៃបោះឆ្នោត (៣៤%) ឬមុន (២៨%)។
- ក្នុងចំណោមស្ត្រី AAPI ដែលមានការពេញចិត្តយ៉ាងខ្លាំងក្នុងការបោះឆ្នោត មានការព្រួយបារម្ភអំពីបញ្ហាជាតិ និងសង្គម (៣០%) ពីការបញ្ចេញសំឡេងរបស់ពួកគេ (១៩%) និងការផ្លាស់ប្តូរទិសដៅនៃប្រទេស (១៧%) គឺជាកត្តាជំរុញទឹកចិត្តបំផុត។
- ក្នុងចំណោមស្ត្រី AAPI ដែលមិនសូវចង់ចូលរួមក្នុងការបោះឆ្នោត មូលហេតុចម្បងគឺថាពួកគេជឿថាប្រព័ន្ធនេះពុករលួយ និងមានការក្លែងបន្លំ (៣០%) ឬមិនចូលចិត្តបេក្ខជន (២៩%)។
- ប្រហែលមួយភាគបី (៣៣%) នៃស្ត្រី AAPI បានឆ្លើយថាពួកគេទំនងជាបោះឆ្នោតឱ្យបេក្ខជនភាគីទីបី (បើប្រៀបធៀបទៅនឹង ២៤% នៃស្ត្រីស្បែកខ្មៅ និង ៣១% នៃស្ត្រីជនជាតិឡាទីន)
- ប៉ុស្តិ៍ព័ត៌មានដូចជា CNN ឬ MSNBC (៣២%) និងទូរទស្សន៍ក្នុងស្រុក (៣១%) គឺជាប្រភពប្រព័ន្ធផ្សព្វផ្សាយកំពូលសម្រាប់ព័ត៌មាន ឬព័ត៌មាននយោបាយសម្រាប់ស្ត្រី AAPI ហើយប្រហែលជា ១ ក្នុងចំណោម ២០ ក្នុងចំណោមពួកគេ (៥%) ជាញឹកញាប់ងាកទៅ កាសែតភាសាសហគមន៍ ។